- បានឃើញប្រកាសលេខ ២៥៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអគ្គនាយក នៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញប្រកាសលេខ ២៨០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាជំពូក៦០ “ការទិញ” និង ជំពូក៦១ “សេវាកម្ម” នៅគណៈកម្មការមូលបត្រកម្ពុជា សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
គណៈកម្មការមូលបត្រកម្ពុជា

## តារាងឧបសម្ព័ន្ធវិភាជន៍ឥណទានថវិកាបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៥ របស់គណៈកម្មការមូលបត្រកម្ពុជា

ឯកតាគិតជារៀល

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជុំបង្វិល រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2-3 | 5=3/4ជុំ | 6=3/2 |
| | | | **សរុប (I+II)** | **847.700.000** | **714.300.000** | **223.603.000** | **490.697.000** | **55.900.750** | **31,3%** |
| I. ឥណទានតាមជំពូកដោយមិនគិតបញ្ចូលចំណាយប្រាក់បៀវត្សកម្មក្នុងប្រទេស | | | | **832.200.000** | **698.800.000** | **208.103.000** | **490.697.000** | **52.025.750** | **29,8%** |
| 60 | | | **ការទិញ** | **229.200.000** | **160.900.000** | **48.203.000** | **112.697.000** | **12.050.750** | **30,0%** |
| | 6001 | | **សម្ភារផ្គត់ផ្គង់ថែទាំ** | **68.300.000** | **-** | **-** | **-** | **-** | **0,0%** |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 68.300.000 | - | - | - | - | **0,0%** |
| | 6002 | | **សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល** | **70.000.000** | **70.000.000** | **21.000.000** | **49.000.000** | **5.250.000** | **30,0%** |
| | | 60021 | សម្ភារការិយាល័យ និងការបោះពុម្ព | 70.000.000 | 70.000.000 | 21.000.000 | 49.000.000 | 5.250.000 | 30,0% |
| | 6004 | | **សំលៀកបំពាក់ និងការតុបតែង** | **7.000.000** | **7.000.000** | **7.000.000** | **-** | **1.750.000** | **100,0%** |
| | | 60041 | ឯកសណ្ឋាន | 7.000.000 | 7.000.000 | 7.000.000 | - | 1.750.000 | 100,0% |

| ជំពូក | គណនី | អនុគណនី | វាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ | ឥណទានដែលជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2-3 | 5=3/4ជុំ | 6=3/2 |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 50.000.000 | 50.000.000 | 15.000.000 | 35.000.000 | 3.750.000 | 30,0% |
| | | 61108 | សោហ៊ុយទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ ផ្សេងៗ | 300.000.000 | 300.000.000 | 27.000.000 | 273.000.000 | 6.750.000 | 9,0% |
| | **6111** | | **ចំណាយលើការជាវសារព័ត៌មាន និងឯកសារ** | **5.500.000** | **3.500.000** | **3.500.000** | **-** | **875.000** | 100,0% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 3.500.000 | 3.500.000 | 3.500.000 | - | **875.000** | 100,0% |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | 2.000.000 | - | - | - | - | 0,0% |
| | **6113** | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | **45.900.000** | **-** | **-** | **-** | - | 0,0% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 26.000.000 | - | - | - | - | 0,0% |
| | | 61132 | សោហ៊ុយបេសកកម្ម | 900.000 | - | - | - | - | 0,0% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 17.400.000 | - | - | - | - | 0,0% |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | 1.600.000 | - | - | - | - | 0,0% |
| | **6114** | | **សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍** | **19.200.000** | **2.000.000** | **2.000.000** | - | **500.000** | 100,0% |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 2.000.000 | 2.000.000 | 2.000.000 | - | **500.000** | 100,0% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 17.200.000 | - | - | - | - | 0,0% |
| **II. ឥណទានសម្រាប់ចំណាយប្រាក់បេសកកម្មក្នុងប្រទេស** | | | | **15.500.000** | **15.500.000** | **15.500.000** | **-** | **3.875.000** | **100,0%** |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ | ឥណទានដែលជ្រើសរើស | ឥណទានរជ្ជទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន១ជំពូក រជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2-3 | 5=3/4ជំ | 6=3/2 |
| | **6005** | | **សម្ភារតូចតាច សង្ហារឹម និងសម្ភារបរិក្ខារ** | **83.900.000** | **83.900.000** | **20.203.000** | **63.697.000** | **5.050.750** | **24,1%** |
| | | 60051 | សម្ភារ និងបរិក្ខារបច្ចេកទេស | 67.600.000 | 67.600.000 | 13.520.000 | 54.080.000 | 3.380.000 | 20,0% |
| | | 60052 | សង្ហារឹម | 16.300.000 | 16.300.000 | 6.683.000 | 9.617.000 | 1.670.750 | 41,0% |
| **61** | | | **សេវាកម្ម** | **603.000.000** | **537.900.000** | **159.900.000** | **378.000.000** | **39.975.000** | **29,7%** |
| | **6105** | | **ការថែទាំ និងជួសជុល** | **40.400.000** | **40.400.000** | **40.400.000** | **-** | **10.100.000** | **100,0%** |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 9.000.000 | 9.000.000 | 9.000.000 | - | 2.250.000 | 100,0% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 2.000.000 | 2.000.000 | 2.000.000 | - | 500.000 | 100,0% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 5.000.000 | 5.000.000 | 5.000.000 | - | 1.250.000 | 100,0% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 24.400.000 | 24.400.000 | 24.400.000 | - | 6.100.000 | 100,0% |
| | **6110** | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | **492.000.000** | **492.000.000** | **114.000.000** | **378.000.000** | **28.500.000** | **23,2%** |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 17.000.000 | 17.000.000 | 17.000.000 | - | 4.250.000 | 100,0% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 15.000.000 | 15.000.000 | 15.000.000 | - | 3.750.000 | 100,0% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 100.000.000 | 100.000.000 | 30.000.000 | 70.000.000 | 7.500.000 | 30,0% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 4.000.000 | 4.000.000 | 4.000.000 | - | 1.000.000 | 100,0% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស | 6.000.000 | 6.000.000 | 6.000.000 | - | 1.500.000 | 100,0% |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជំពូបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | 1 | 2 | 3 | 4=2-3 | 5=3/4ជំ | 6=3/2 |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 15.500.000 | 15.500.000 | 15.500.000 | - | 3.875.000 | 100,0% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 4.200.000 | 4.200.000 | 4.200.000 | - | 1.050.000 | 100,0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 1.700.000 | 1.700.000 | 1.700.000 | - | 425.000 | 100,0% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 9.600.000 | 9.600.000 | 9.600.000 | - | 2.400.000 | 100,0% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី...ខែ...ឆ្នាំ២០១៥
ប. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
ម៉ិញ បានសុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី...ខែ...ឆ្នាំ២០១៥
អគ្គនាយក
ត.អគ្គនាយកដ្ឋានថវិកា
ម៉ែន_សុធ្លាវិ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី...ខែ...ឆ្នាំ២០១៥
អគ្គនាយក
គណៈកម្មការមូលបត្រកម្ពុជា
ស៊ូ សុជាតិ

ថ្ងៃទី...ខែ...ឆ្នាំ២០១៥
រដ្ឋទេយ្យករបុរេប្រទាន
ឈុន សម្បត្តិ

បានឃើញ និងឯកភាព
ថ្ងៃទី...ខែ...ឆ្នាំ២០១៥
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ឧបនាយករដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible].....សហវ. [illegible]

## ប្រកាស
## ស្តីពី
## ការបង្កើតរង្វាន់ឧបត្ថម្ភប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងអង្គភាពថវិកា អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92. Sangkat Wat Phnom , khan Daun Penh. Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ២៧៩ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិរៀបចំនិងអនុវត្តថវិការជ្ជទេយ្យបុរេប្រទាន ជូនអង្គភាពថវិកាដែលមិនមែនជាអាណាប័កផ្ទេរសិទ្ធិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ២៨០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានជំពូក៦០ "ការទិញ" ជំពូក៦១ "សេវាកម្ម" និងជំពូក៦៤ "បន្ទុកបុគ្គលិក" នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងអង្គភាពថវិកា អគ្គលេខាធិការដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប៉ុន្តែមិនរួមបញ្ចូលអង្គភាពថវិកាដទៃទៀតនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីកំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាស ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គលេខាធិការដ្ឋាន

## ឧបសម្ព័ន្ធវិជ្ជទេយ្យបុរេប្រទានសម្រាប់ចំណាយចាំបាច់ក្នុងឆ្នាំ២០១៥

"ឯកតាគិត: រៀលគត់"

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ ១ | ឥណទាន ដែលជ្រើសរើស ២ | ឥណទាន វិជ្ជទេយ្យបុរេប្រទាន ៣ | ឥណទាន ទូទាត់ធម្មតា ៤=២-៣ | ឥណទាន០១ដំបូងនៃ វិជ្ជទេយ្យបុរេប្រទាន ៥=៣/៤ដំ | ភាគរយ ៦=៣/២ |
|---|---|---|---|---|---|---|---|---|---|
| | | | សរុប I + II | 141,649,300,000.0 | 7,944,400,000.0 | 2,771,648,000.0 | 5,172,752,000.0 | 692,912,000.0 | 34.89% |
| I. ឥណទានតាមជំពូក ដោយមិនគិតបញ្ចូលចំណាយប្រាក់បៀវត្សក្នុងប្រទេស | | | | 141,088,700,000.0 | 7,383,800,000.0 | 2,211,048,000.0 | 5,172,752,000.0 | 552,762,000.0 | 29.94% |
| 60 | | | ការទិញ | 7,194,000,000.0 | 1,793,600,000.0 | 534,660,000.0 | 1,258,940,000.0 | 133,665,000.0 | 29.81% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 1,048,000,000.0 | 197,600,000.0 | 67,260,000.0 | 130,340,000.0 | 16,815,000.0 | 34.04% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់សម្អាតនិងអនាម័យ | 51,900,000.0 | 51,900,000.0 | 31,140,000.0 | 20,760,000.0 | 7,785,000.0 | 60.00% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ | 75,900,000.0 | 75,900,000.0 | 15,180,000.0 | 60,720,000.0 | 3,795,000.0 | 20.00% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 69,800,000.0 | 69,800,000.0 | 20,940,000.0 | 48,860,000.0 | 5,235,000.0 | 30.00% |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 850,400,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 570,000,000.0 | 570,000,000.0 | 239,600,000.0 | 330,400,000.0 | 59,900,000.0 | 42.04% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 465,000,000.0 | 465,000,000.0 | 204,600,000.0 | 260,400,000.0 | 51,150,000.0 | 44.00% |
| | | 60022 | សៀវភៅមើលនិងឯកសារ | 100,000,000.0 | 100,000,000.0 | 30,000,000.0 | 70,000,000.0 | 7,500,000.0 | 30.00% |
| | | 60028 | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ | 5,000,000.0 | 5,000,000.0 | 5,000,000.0 | 0.0 | 1,250,000.0 | 100.00% |
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | 120,000,000.0 | 120,000,000.0 | 36,000,000.0 | 84,000,000.0 | 9,000,000.0 | 30.00% |
| | | 60041 | ឯកសណ្ឋាន | 120,000,000.0 | 120,000,000.0 | 36,000,000.0 | 84,000,000.0 | 9,000,000.0 | 30.00% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 1,306,000,000.0 | 906,000,000.0 | 191,800,000.0 | 714,200,000.0 | 47,950,000.0 | 21.17% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 600,000,000.0 | 600,000,000.0 | 120,000,000.0 | 480,000,000.0 | 30,000,000.0 | 20.00% |
| | | 60052 | សង្ហារឹម | 200,000,000.0 | 200,000,000.0 | 40,000,000.0 | 160,000,000.0 | 10,000,000.0 | 20.00% |
| | | 60053 | សម្ភារៈប្រើប្រាស់ | 56,000,000.0 | 56,000,000.0 | 16,800,000.0 | 39,200,000.0 | 4,200,000.0 | 30.00% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | 60054 | សម្ភារៈនិងឧបករណ៍ដឹកជញ្ជូន | 400,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 60058 | សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខារផ្សេងៗ | 50,000,000.0 | 50,000,000.0 | 15,000,000.0 | 35,000,000.0 | 3,750,000.0 | 30.00% |
| | 6006 | | ថាមពល និងទឹក | 4,150,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 60061 | អគ្គិសនី | 4,000,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 60062 | ទឹក | 150,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| 61 | | | សេវាកម្ម | 6,798,500,000.0 | 5,438,200,000.0 | 1,630,788,000.0 | 3,807,412,000.0 | 407,697,000.0 | 29.99% |
| | 6101 | | កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 20,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 20,000,000.0 | 20,000,000.0 | 6,000,000.0 | 14,000,000.0 | 1,500,000.0 | 30.00% |
| | 6103 | | ថ្លៃឈ្នួលនិងបន្ទុក(អសង្ហារឹម) | 100,300,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | 6104 | | សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក ក្នុងនិងក្រៅប្រទេស | 2,800,000.0 | 2,800,000.0 | 840,000.0 | 1,960,000.0 | 210,000.0 | 30.00% |
| | 6105 | | ការថែទាំ និងជួសជុល | 1,501,600,000.0 | 1,501,600,000.0 | 450,480,000.0 | 1,051,120,000.0 | 112,620,000.0 | 30.00% |
| | | 61051 | ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែនទេសាទ | 149,700,000.0 | 149,700,000.0 | 44,910,000.0 | 104,790,000.0 | 11,227,500.0 | 30.00% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 599,600,000.0 | 599,600,000.0 | 179,880,000.0 | 419,720,000.0 | 44,970,000.0 | 30.00% |
| | | 61053 | ការថែទាំនិងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 52,000,000.0 | 52,000,000.0 | 15,600,000.0 | 36,400,000.0 | 3,900,000.0 | 30.00% |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 299,900,000.0 | 299,900,000.0 | 89,970,000.0 | 209,930,000.0 | 22,492,500.0 | 30.00% |
| | | 61056 | ការថែទាំនិងជួសជុលមធ្យោបាយដឹកជញ្ជូន | 229,500,000.0 | 229,500,000.0 | 68,850,000.0 | 160,650,000.0 | 17,212,500.0 | 30.00% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 119,400,000.0 | 119,400,000.0 | 35,820,000.0 | 83,580,000.0 | 8,955,000.0 | 30.00% |
| | | 61058 | ការថែទាំនិងជួសជុលផ្សេងៗ | 51,500,000.0 | 51,500,000.0 | 15,450,000.0 | 36,050,000.0 | 3,862,500.0 | 30.00% |
| | 6107 | | សោហ៊ុយពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 61071 | សោហ៊ុយសិក្សាពិសោធន៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 61072 | សោហ៊ុយនៃការប្រើប្រាស់សេវា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 61078 | សោហ៊ុយផ្សេងៗទៀត | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន វជ្ជទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ដុំបង្គិល វជ្ជទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | 61081 | សម្ភារៈនិងទិនិញ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | **6109** | | **បុគ្គលិកខាងក្រៅ** | **80,000,000.0** | **80,000,000.0** | **24,000,000.0** | **56,000,000.0** | **6,000,000.0** | **30.00%** |
| | | 61091 | ភ្នាក់ងារជាតិជាប់កិច្ចសន្យា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 61093 | បុគ្គលិកសម្ភហភាពសាធារណៈផ្សេងៗ | 80,000,000.0 | 80,000,000.0 | 24,000,000.0 | 56,000,000.0 | 6,000,000.0 | 30.00% |
| | | 61098 | បុគ្គលិកខាងក្រៅផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | **6110** | | **ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ** | **1,815,400,000.0** | **1,815,400,000.0** | **544,620,000.0** | **1,270,780,000.0** | **136,155,000.0** | **30.00%** |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 499,400,000.0 | 499,400,000.0 | 149,820,000.0 | 349,580,000.0 | 37,455,000.0 | 30.00% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 300,000,000.0 | 300,000,000.0 | 90,000,000.0 | 210,000,000.0 | 22,500,000.0 | 30.00% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 150,800,000.0 | 150,800,000.0 | 45,240,000.0 | 105,560,000.0 | 11,310,000.0 | 30.00% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 500,000,000.0 | 500,000,000.0 | 150,000,000.0 | 350,000,000.0 | 37,500,000.0 | 30.00% |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស | 160,000,000.0 | 160,000,000.0 | 48,000,000.0 | 112,000,000.0 | 12,000,000.0 | 30.00% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 61108 | សោហ៊ុយទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយផ្សេងៗ | 205,200,000.0 | 205,200,000.0 | 61,560,000.0 | 143,640,000.0 | 15,390,000.0 | 30.00% |
| | **6111** | | **ចំណាយលើការជាវសារព័ត៌មាន និងឯកសារ** | **90,300,000.0** | **90,300,000.0** | **26,418,000.0** | **63,882,000.0** | **6,604,500.0** | **29.26%** |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 400,000.0 | 400,000.0 | 400,000.0 | 0.0 | 100,000.0 | 100.00% |
| | | 61112 | ចំណាយលើការជាវទស្សនាវដ្ដី | 900,000.0 | 900,000.0 | 900,000.0 | 0.0 | 225,000.0 | 100.00% |
| | | 61113 | ចំណាយលើការជាវសៀវភៅរាជកិច្ច | 9,900,000.0 | 9,900,000.0 | 2,970,000.0 | 6,930,000.0 | 742,500.0 | 30.00% |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាននិងឯកសារផ្សេងៗ | 79,100,000.0 | 79,100,000.0 | 22,148,000.0 | 56,952,000.0 | 5,537,000.0 | 28.00% |
| | **6113** | | **ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស** | **1,908,100,000.0** | **1,908,100,000.0** | **572,430,000.0** | **1,335,670,000.0** | **143,107,500.0** | **30.00%** |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 555,900,000.0 | 555,900,000.0 | 166,770,000.0 | 389,130,000.0 | 41,692,500.0 | 30.00% |
| | | 61132 | សោហ៊ុយបេសកកម្ម | 587,800,000.0 | 587,800,000.0 | 176,340,000.0 | 411,460,000.0 | 44,085,000.0 | 30.00% |
| | | 61133 | សោហ៊ុយស្នាក់នៅ | 715,200,000.0 | 715,200,000.0 | 214,560,000.0 | 500,640,000.0 | 53,640,000.0 | 30.00% |
| | | 61138 | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេសផ្សេងៗ | 49,200,000.0 | 49,200,000.0 | 14,760,000.0 | 34,440,000.0 | 3,690,000.0 | 30.00% |
| | **6114** | | **សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍** | **320,000,000.0** | **20,000,000.0** | **6,000,000.0** | **14,000,000.0** | **1,500,000.0** | **30.00%** |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ដុំបង្គិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដុំ | ៦=៣/២ |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 20,000,000.0 | 20,000,000.0 | 6,000,000.0 | 14,000,000.0 | 1,500,000.0 | 30.00% |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 800,000,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | 6115 | | **សោហ៊ុយធនាគារ** | **440,000,000.0** | **0.0** | **0.0** | **0.0** | **0.0** | **#DIV/0!** |
| | 6198 | | **សោហ៊ុយនិងសេវាកម្មផ្សេងៗ** | **0.0** | **0.0** | **0.0** | **0.0** | **0.0** | **#DIV/0!** |
| 64 | | | **បន្ទុកបុគ្គលិក** | **47,134,600,000.0** | **152,000,000.0** | **45,600,000.0** | **106,400,000.0** | **11,400,000.0** | **30.00%** |
| | 6401 | | **លាភការនិងប្រាក់បំណាច់នៃអិណាចាធារណៈ** | **1,029,900,000.0** | **0.0** | **0.0** | **0.0** | **0.0** | **#DIV/0!** |
| | | 64014 | ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ | 378,000,000.0 | | | | | #DIV/0! |
| | | 64016 | លាភការប្រឹក្សា | 538,200,000.0 | | | | | #DIV/0! |
| | | 64018 | លាភការអ្នកជំនួយការ | 113,700,000.0 | | | | | #DIV/0! |
| | 6402 | | **លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍** | **44,470,200,000.0** | **0.0** | **0.0** | **0.0** | **0.0** | **#DIV/0!** |
| | | 64021 | បៀវត្សមូលដ្ឋាន | 29,676,400,000.0 | | | | | #DIV/0! |
| | | 64022 | ប្រាក់បំណាច់មុខងារ | 13,384,800,000.0 | | | | | #DIV/0! |
| | | 64023 | ប្រាក់បំណាច់ម៉ោងបន្ថែម | 1,120,000,000.0 | | | | | #DIV/0! |
| | | 64026 | ប្រាក់បំណាច់តំបន់ | 15,000,000.0 | | | | | #DIV/0! |
| | | 64027 | ប្រាក់បំណាច់ទទួលខុសត្រូវ | 269,000,000.0 | | | | | #DIV/0! |
| | | 64028 | ប្រាក់បំណាច់ការងារធ្ងន់និងប៉ះពាល់សុខភាព | 5,000,000.0 | | | | | #DIV/0! |
| | 6403 | | **រង្វាន់និងប្រាក់បំណាច់ផ្សេងៗ** | **456,000,000.0** | **0.0** | **0.0** | **0.0** | **0.0** | **#DIV/0!** |
| | | 64033 | រង្វាន់ | | | | | | #DIV/0! |
| | | 64034 | ប្រាក់បំណាច់បុគ្គលិកអង្គភាពផ្សេងៗ | 456,000,000.0 | | | | | #DIV/0! |
| | 6404 | | **លាភការនិងប្រាក់បំណាច់បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍** | **188,500,000.0** | **0.0** | **0.0** | **0.0** | **0.0** | **#DIV/0!** |
| | | 64C41 | បៀវត្សមូលដ្ឋានបុគ្គលិកជាប់កិច្ចសន្យា | 104,500,000.0 | | | | | #DIV/0! |
| | | 64C43 | បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត | 84,000,000.0 | | | | | #DIV/0! |
| | 6405 | | **ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ** | **729,600,000.0** | **152,000,000.0** | **45,600,000.0** | **106,400,000.0** | **11,400,000.0** | **30.00%** |
| | | 64C51 | មន្ត្រីមានជំងឺ | 50,000,000.0 | 50,000,000.0 | 15,000,000.0 | 35,000,000.0 | 3,750,000.0 | 30.00% |

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១០ភាគរយ រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ដង | ៦=៣/២ |
| | | 64052 | អ្នកសំរាលកូន | 40,000,000.0 | 40,000,000.0 | 12,000,000.0 | 28,000,000.0 | 3,000,000.0 | 30.00% |
| | | 64053 | មរណៈភាព | 50,000,000.0 | 50,000,000.0 | 15,000,000.0 | 35,000,000.0 | 3,750,000.0 | 30.00% |
| | | 64054 | ឧបត្ថម្ភនិវត្តជន | 519,100,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 64055 | ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ | 58,500,000.0 | 0.0 | 0.0 | 0.0 | 0.0 | #DIV/0! |
| | | 64056 | គ្រោះថ្នាក់ក្នុងការងារនិងទុព្វលភាព | 12,000,000.0 | 12,000,000.0 | 3,600,000.0 | 8,400,000.0 | 900,000.0 | 30.00% |
| | **6406** | | **ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ** | **260,400,000.0** | | | | | #DIV/0! |
| | | 64061 | កូនមានអាយុក្រោម ១៥ឆ្នាំ | 76,000,000.0 | | | | | #DIV/0! |
| | | 64062 | កូនរៀនអនុវិទ្យាល័យ វិទ្យាល័យ | 76,000,000.0 | | | | | #DIV/0! |
| | | 64063 | ប្រាក់បំណាច់អ្នកក្នុងបន្ទុក | 108,400,000.0 | | | | | #DIV/0! |
| **62** | | | **អត្ថប្រយោជន៍សង្គម** | **6,250,000,000.0** | | | | | #DIV/0! |
| | **6202** | | **ជំនួយសង្គមដល់ប្រជាពលរដ្ឋ** | **6,250,000,000.0** | | | | | #DIV/0! |
| | | 62023 | អាហារនិងសម្ភារៈ (សៀងបំរុងរដ្ឋ) | 6,250,000,000.0 | | | | | #DIV/0! |
| **65** | | | **ឧបត្ថម្ភធន** | **18,610,000,000.0** | | | | | #DIV/0! |
| | **6502** | | **ឧបត្ថម្ភធនដល់អង្គការសាធារណៈ** | **1,400,000,000.0** | | | | | #DIV/0! |
| | | 65021 | ឧបត្ថម្ភធនដល់អង្គការដែលមានលក្ខណៈសេដ្ឋកិច្ច | 1,400,000,000.0 | | | | | #DIV/0! |
| | **6506** | | **វិភាគទានដល់អង្គការអន្តរជាតិនានា** | **17,210,000,000.0** | | | | | #DIV/0! |
| | | 65062 | ធនាគារពិភពលោក | 2,885,000,000.0 | | | | | #DIV/0! |
| | | 65063 | ធនាគារអភិវឌ្ឍន៍អាស៊ី | 1,200,000,000.0 | | | | | #DIV/0! |
| | | 65068 | អង្គការអន្តរជាតិផ្សេងៗទៀត | 13,125,000,000.0 | | | | | #DIV/0! |
| **63** | | | **ពន្ធនិងអាករ** | **55,101,600,000.0** | | | | | **#DIV/0!** |
| | **6301** | | **លតាប័ត្រ** | **101,600,000.0** | | | | | **#DIV/0!** |
| | **7009** | | **ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ** | **55,000,000,000.0** | | | | | #DIV/0! |
| **II. ឥណទានសម្រាប់ចំណាយប្រាក់បេសកកម្មក្នុងប្រទេស** | | | | **560,600,000.0** | **560,600,000.0** | **560,600,000.0** | **0.0** | **140,150,000.0** | **100.00%** |
| **61** | | | សេវាកម្ម | **560,600,000.0** | **560,600,000.0** | **560,600,000.0** | **0.0** | **140,150,000.0** | **100.00%** |

5

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤= ២- ៣ - | ៥= ៣/ ៤ជុំ | ៦= ៣/ ២ |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 560,600,000.0 | 560,600,000.0 | 560,600,000.0 | 0.0 | 140,150,000.0 | 100.00% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 200,400,000.0 | 200,400,000.0 | 200,400,000.0 | 0.0 | 50,100,000.0 | 100.00% |
| | | 61122 | សោហ៊ុយបេសកកម្ម | 84,000,000.0 | 84,000,000.0 | 84,000,000.0 | 0.0 | 21,000,000.0 | 100.00% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 256,400,000.0 | 256,400,000.0 | 256,400,000.0 | 0.0 | 64,100,000.0 | 100.00% |
| | | 61128 | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេសផ្សេងៗ | 19,800,000.0 | 19,800,000.0 | 19,800,000.0 | 0.0 | 4,950,000.0 | 100.00% |

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៥
ជ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង

ម៉ិញ បានសុវណ្ណអាទិច្ចាសីលា

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០១៥
ជ-អគ្គនាយក
អគ្គនាយកដ្ឋានថវិកា

ម៉ែន_សុន្ធារី

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០១៥
អគ្គលេខាធិការ
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត ហ៊ែល ចំរើន

បានឃើញនិងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៥
ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

ឯក ចន្ថា

ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ២០១៥
រដ្ឋទេយ្យករបុរេប្រទានរង

បានឃើញ និងឯកភាព
ថ្ងៃទី០៥ ខែ ឧសភា ឆ្នាំ២០១៥
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ..០០៥......សហវ.......

## សារាចរ
## ស្តីពីការកែតម្រូវ
## សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពី ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងគោលដៅធានាសង្គតិភាព នៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការប្រមូលចំណូលពីកម្រៃសេវាសុរិយោដី និងសេវាសំណង់ សារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកែតម្រូវត្រង់ចំណុចខ.២ ចំណុចទី២ ត្រៃទី២ តាមខ្លឹមសារទាំងស្រុង ដូចតទៅ÷

"- ចំណូលបានមកពីសេវាសុរិយោដី និងសេវាសំណង់ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសរួមលេខ ៩៩៥ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រកាសរួមលេខ ៩៩៦ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។"

ខ្លឹមសារផ្សេងទៀតនៃសារាចរណែនាំលេខ ០១៣ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ត្រូវបន្តស្ថិតនៅជាធរមាន។

សារាចរនេះ មានអានុភាពអនុវត្ត ចំពោះការប្រមូលចំណូលពីសេវាសុរិយោដី និងសេវាសំណង់ ក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិត. **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- គ្រប់រតនាគាររាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-724 664 Fax : 855-23-427 798

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ០៩៩/ប្រក កសក

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ថ្នាំកសិកម្មនិងជីកសិកម្ម

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញប្រកាសលេខ១១៩ ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការគ្រប់គ្រងជីកសិកម្ម ដែលត្រូវធ្វើពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ១២០ប្រក.កសក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការគ្រប់គ្រងថ្នាំកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ១៧៦ ប្រក.កសក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការធ្វើអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្ម
- បានឃើញប្រកាសអន្តរក្រសួងលេខ៩៦ កយ.កសក.ប្រក/១៣ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌
- បានឃើញប្រកាសលេខ១៩៩ ប្រក.កសក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនិងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងធានាគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពនៃថ្នាំកសិកម្មនិងជីកសិកម្មដែលត្រូវនាំចូលនាំចេញ ឬត្រូវលាយផ្សំឬវេចខ្ចប់ជាថ្មី និងធានាអនុវត្តការតម្រូវបមាណីយសម្រាប់ផលិតផលថ្នាំកសិកម្មនិងជីកសិកម្មដែលត្រូវធ្វើពាណិជ្ជកម្ម នៅមុនពេលផ្គត់ផ្គង់ចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារផលប្រយោជន៍របស់កសិករនិងអ្នកប្រើប្រាស់ចុងក្រោយនៅក្នុងផលិតកម្មកសិកម្ម ឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅ៖

- កំណត់នីតិវិធីនៃការត្រួតពិនិត្យដើមគ្រា និងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្មនិងជីកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកស័កម្ម

- ផ្តល់នូវគោលការណ៍រួមនិងនីតិវិធីឯកភាពសម្រាប់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ច ដើម្បីអនុវត្តនៅក្នុងប្រតិបត្តិការអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មដែលធ្វើពាណិជ្ជកម្មនាំចូលនាំចេញ លាយផ្សំឬវេចខ្ចប់ជាថ្មី នៅមុនពេលផ្គត់ផ្គង់ចែកចាយសម្រាប់ការប្រើប្រាស់ក្នុងផលិតកម្មកសិកម្ម ឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះថ្នាំកសិកម្មនិងជីកសិកម្មគ្រប់ប្រភេទ ដែលត្រូវធ្វើការនាំចូលនាំចេញ ការលាយផ្សំ ការវេចខ្ចប់ជាថ្មី នៅមុនពេលផ្គត់ផ្គង់ចែកចាយសម្រាប់ការប្រើប្រាស់នៅក្នុងផលិតកម្មកសិកម្ម ឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ ៤.-**

នាយកដ្ឋាននីតិកម្មកសិកម្ម ជាអង្គភាពមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យដើមគ្រា។ នាយកដ្ឋាននីតិកម្មកសិកម្ម ផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ នូវថ្នាំកសិកម្មឬជីកសិកម្មដែលធ្វើប្រតិបត្តិការពាណិជ្ជកម្ម នាំចូលនាំចេញ លាយផ្សំឬវេចខ្ចប់ជាថ្មី នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬសម្រាប់ការនាំចេញពីព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីទទួលបានការឯកភាពពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៥.-**

មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មនៃនាយកដ្ឋាននីតិកម្មកសិកម្ម ដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ បំពេញភារកិច្ច និងមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យដើមគ្រាថ្នាំកសិកម្មឬជីកសិកម្ម ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងប្រកាសនេះ។

## ជំពូកទី៣
## នីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងការផ្តល់សុពលភាព ផ្គត់ផ្គង់ចែកចាយ

### ផ្នែកទី១៖ នីតិវិធីរួម

**ប្រការ ៦.-**

រាល់ផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ដែលត្រូវធ្វើការផ្គត់ផ្គង់ចែកចាយ នាំចូលនាំចេញ លាយផ្សំ ឬវេចខ្ចប់ជាថ្មី ចាំបាច់ត្រូវឆ្លងកាត់នីតិវិធីនៃការត្រួតពិនិត្យដើមគ្រានិងការផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងប្រកាសនេះ។

**ប្រការ ៧.-**

ប្រតិបត្តិករដែលធ្វើការនាំចូលនាំចេញ ធ្វើការលាយផ្សំ ឬធ្វើការវេចខ្ចប់ជាថ្មីនូវផលិតផលថ្នាំកសិកម្មឬជីកសិកម្ម ត្រូវធ្វើលិខិតប្រតិវេទន៍ជាចាំបាច់ជូននាយកដ្ឋាននីតិកម្មកសិកម្ម នូវផលិតផលដែលត្រូវធ្វើការនាំចូលនាំចេញ ធ្វើការលាយផ្សំឬការវេចខ្ចប់ជាថ្មី ដោយភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធ។

ផលិតផលថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍ នៅពេលធ្វើការនាំចូលនាំចេញ ការលាយផ្សំឬវេចខ្ចប់ជាថ្មី ត្រូវដកយកសំណាកដើម្បីធ្វើវិភាគផ្ទៀងផ្ទាត់និងត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តការតម្រូវបមាណីយ និងកាតព្វកិច្ចផ្សេងទៀតរបស់ប្រតិបត្តិករ ដើម្បីទទួលបានសុពលភាពផ្គត់ផ្គង់ចែកចាយ ឬធ្វើការនាំចេញ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

**ប្រការ ៨.-**

លិខិតប្រតិវេទន៍ត្រូវមានខ្លឹមសារដូចខាងក្រោម៖

- អត្តសញ្ញាណក្រុមហ៊ុនឬប្រតិបត្តិករដែលធ្វើប្រតិវេទន៍
- យថាប្រភេទ បរិមាណនៃថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិបត្តិការ
- មាត់ច្រក កំពង់ផែដែលត្រូវធ្វើប្រតិបត្តិការនាំចូលនាំចេញ
- ទីតាំងនិងអាសយដ្ឋានគ្រឹះស្ថានលាយផ្សំឬវេចខ្ចប់ជាថ្មីផលិតផលថ្នាំកសិកម្មឬជីកសិកម្ម
- ចំនួនទីតាំងនិងអាសយដ្ឋានឃ្លាំងសន្និធិថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍
- ប្រភេទ ចំនួន មធ្យោបាយដឹកជញ្ជូនដែលមានអត្តសញ្ញាណច្បាស់លាស់
- កាលបរិច្ឆេទ ពេលវេលាដែលមធ្យោបាយដឹកជញ្ជូនថ្នាំកសិកម្មឬជីកសិកម្មមកដល់ ឬនឹងត្រូវដឹកចេញពីឃ្លាំងសន្និធិដែលត្រូវត្រួតពិនិត្យ។

គំរូលិខិតប្រតិវេទន៍លើប្រតិបត្តិការពាក់ព័ន្ធនឹងថ្នាំកសិកម្មឬជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី១នៃប្រកាសនេះ។

**ប្រការ ៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើប្រតិវេទន៍ អំពីប្រតិបត្តិការពាក់ព័ន្ធថ្នាំកសិកម្មឬជីកសិកម្ម មានកាតព្វកិច្ច ដូចខាងក្រោម៖

១- ត្រូវអនុញ្ញាតនិងផ្តល់កិច្ចសហការឲ្យមន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មមានសមត្ថកិច្ចធ្វើការត្រួតពិនិត្យ។

២- ត្រូវបង្ហាញលិខិតអនុញ្ញាតនិងវិញ្ញាបនបត្រពាក់ព័ន្ធប្រតិបត្តិការរបស់ខ្លួន លិខិតប្រតិវេទន៍កំណត់ត្រាពាណិជ្ជកម្មតាមប្រតិបត្តិការនីមួយៗ និងឯកសារពាក់ព័ន្ធផ្សេងទៀត តាមការតម្រូវ ដោយអនុលោមតាមនីតិវិធីនៃប្រកាសនេះ។

៣- ត្រូវឆ្លើយបំភ្លឺ ពន្យល់ និងផ្តល់ព័ត៌មានឬឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការ ថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍។

៤- ត្រូវបំពេញឬឆ្លើយតបនឹងបញ្ជីសំណួរ របស់មន្ត្រីអធិការកិច្ចថ្នាំកសិកម្មនិងជីកសិកម្មពាក់ព័ន្ធនឹងប្រតិបត្តិការថ្នាំកសិកម្មឬជីកសិកម្មដែលត្រូវធ្វើប្រតិវេទន៍។

៥- ត្រូវផ្តល់សំណាកថ្នាំកសិកម្មឬជីកសិកម្មសម្រាប់ការធ្វើវិភាគផ្ទៀងផ្ទាត់ និងចូលរួមបំពេញសំណុំបែបបទនៅក្នុងដំណើរការត្រួតពិនិត្យ។

៦- ត្រូវបំពេញកាតព្វកិច្ចផ្សេងទៀតក្នុងក្របខ័ណ្ឌ នៃការត្រួតពិនិត្យដើមគ្រាថ្នាំកសិកម្មឬជីកសិកម្ម ដោយអនុលោមតាមបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងប្រកាសនេះ។

**ប្រការ ១០.-**

